ការយល់ឃើញរបស់សាធារណជនអំពី សេរីភាពមូលដ្ឋាន ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២៣

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ជាគម្រោងឃ្លាំមើលលំហសង្គមស៊ីវិលនៅកម្ពុជា។ គម្រោងឃ្លាំមើលទៅលើលទ្ធភាពរបស់បុគ្គលដែលអាចអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ ជារៀងរាល់ឆ្នាំ គម្រោងធ្វើការស្ទង់មតិជាសាធារណៈដើម្បីវាស់អំពីការយល់ដឹងរបស់បុគ្គលម្នាក់ៗទៅលើសេរីភាពមូល ដ្ឋានរបស់ខ្លួន និងកម្រិតនៃការអនុវត្តសេរីភាពទាំងនេះ។

គម្រោងប្រើវិធីសាស្ត្រជ្រើសរើសសំណាកងាយៗ។ ការស្ទង់មតិធ្វើឡើងជាមួយពលរដ្ឋគ្រប់ខេត្តដែលមានគោលដៅស្រង់យកមតិពីសាធារណជនទៅតាមក្រុមអាយុ និងយេនឌ័រ។ នៅក្នុងឆ្នាំ២០២៣ គម្រោងបានស្ទង់មតិជាមួយពលរដ្ឋចំនួន១០០៥ នាក់។ ជារៀងរាល់ឆ្នាំ ការស្ទង់មតិធ្វើឡើងជាមួយមនុស្សជាមធ្យមចំនួន ១០០០នាក់ ។



នៅឆ្នាំ២០២៣ ភាគរយអ្នកឆ្លើយតបថាមានសេរីភាពក្នុងការនិយាយនៅទីសាធារណៈបានថយចុះមកត្រឹម ៥៣% ដោយថយចុះ២% ពីឆ្នាំ២០២២។ នេះមានន័យថា ស្ទើរតែ១ក្នុងចំណោមមនុស្ស២នាក់ មិនអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិបានពេញលេញ។



៤០% នៃអ្នកឆ្លើយតបយល់ថាមានសេរីភាពចូលរួមសកម្មភាពនយោបាយបានថយចុះ ៤% ពីឆ្នាំ២០២២។ ភាគច្រើននៃពលរដ្ឋយល់ថាមានការរឹតត្បិតក្នុងការចូលរួមសកម្មភាពនយោបាយរបស់ខ្លួន។ ដោយមានតែ ៤០% ប៉ុណ្ណោះយល់ថាមានទំនុកចិត្តក្នុងការចូលរួមសកម្មភាពនយោបាយក្នុងឆ្នាំ២០២៣ ដែលជាអំឡុងពេលបោះឆ្នោតជាតិ បង្កជាការបារម្ភទាក់ទងនឹងសមត្ថភាពក្នុងការចូលរួមការបោះឆ្នោតដោយសេរី និងយុត្តិធម៌ពិតប្រាកដ នៅក្នុងបរិយាកាសដែលការចូលរួមរបស់ពលរដ្ឋមានកម្រិត។



ភាគរយអ្នកឆ្លើយតបថាមានសេរីភាពក្នុងការធ្វើកូដកម្មដោយសន្តិវិធីបានថយចុះមកត្រឹម ៣០% ក្នុងឆ្នាំ២០២៣។ ការថយចុះនេះបង្កជាការព្រួយបារម្ភពីព្រោះការធ្វើកូដកម្មគឺជាមធ្យោបាយមូលដ្ឋាននៃការអនុវត្តសេរីភាពខាងការជួបប្រជុំ។ ទោះបីជាយ៉ាងនេះក្តី នៅឆ្នាំ២០២៣ គម្រោងបានកត់ត្រាកូដកម្មចំនួន៣ប៉ុណ្ណោះ។

កម្រិតការយល់ដឹងអំពីសេរីភាពមូលដ្ឋានរបស់សាធារណជន



តួលេខខាងក្រោមនេះជាការពិនិត្យកម្រិតការយល់ដឹងរបស់សាធារណជនលើសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំ។

- សេរីភាពខាងសមាគម



ក្នុងឆ្នាំ២០២៣ អ្នកឆ្លើយតប ដែលឆ្លើយត្រឹមត្រូវថា ជារឿងខុសច្បាប់ចំពោះការបង្កើតអង្គការដោយមិនចុះបញ្ជីគឺមាន៧៩%។ ហើយមានតែ ២៧% ប៉ុណ្ណោះដែលឆ្លើយត្រឹមត្រូវថាជារឿងស្របច្បាប់ចំពោះការធ្វើសកម្មភាពរបស់សមាគមដោយមិនបាច់ជូនដំណឹងទៅអាជ្ញាធរ។ ការយល់ខុសដ៏ច្រើននេះ ជំរុញឱ្យបរិយាកាសកាន់តែអាក្រក់ថែមទៀត។ ទី១ រារាំងពលរដ្ឋពីការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន។ ទី២ ផ្តល់ឱកាសដល់អាជ្ញាធរក្នុងការជ្រៀតជ្រែកសកម្មភាពដោយមិនសមរម្យ ដើម្បីរារាំងសកម្មភាពដែលទាក់ទងនឹងការអនុវត្តសេរីភាពខាងសមាគម។ បន្ថែមពីនេះ ច្បាប់អន្តរជាតិទទួលស្គាល់សិទ្ធិបុគ្គលក្នុងការប្រតិបត្តិការអង្គការដោយមិនចាំបាច់ការចុះបញ្ជី។

-សេរីភាពខាងការបញ្ចេញមតិ



នៅឆ្នាំ២០២៣ អ្នកឆ្លើយតប ៨៩% បានឆ្លើយត្រឹមត្រូវថា តាមច្បាប់កម្ពុជាជារឿងខុសច្បាប់ក្នុងការប្រមាថបុគ្គលសាធារណៈ(មិនស្របតាមស្តង់ដារច្បាប់សិទ្ធិមនុស្សអន្តរជាតិ)។ ហើយមានអ្នកឆ្លើយតប ៥៧% ដែលឆ្លើយត្រឹមត្រូវថាជារឿងស្របច្បាប់ក្នុងការរិះគន់គោលនយោបាយរបស់រដ្ឋាភិបាល។ ទន្ទឹមនឹងនេះដែរ ភាគរយនៃអ្នកដែលឆ្លើយត្រឹមត្រូវថាការដកែពីនយោបាយ ជារឿងស្របច្បាប់គឺថយចុះមកត្រឹម៦៧% ។

- សេរីភាពខាងការជួបប្រជុំ



ទិន្នន័យពីឆ្នាំ២០២៣ បង្ហាញពីការកើនឡើង ៨% ពីឆ្នាំ២០២២ នៃចំនួនពលរដ្ឋដែលឆ្លើយត្រឹមត្រូវថាការតវ៉ាដោយសន្តិវិធីជាសកម្មភាពស្របច្បាប់។ ទោះជាយ៉ាងណាក៏ដោយ គម្លាតការយល់ដឹងនៅតែបន្តកើតមាន ដោយសារ មានត្រឹមតែ ៣៣% ប៉ុណ្ណោះនៃអ្នកឆ្លើយតបដែលឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការធ្វើកូដកម្មដោយគ្មានការអនុញ្ញាតជាមុនពីអាជ្ញាធរ។ របត់ទាំងនេះបង្ហាញពីតម្រូវការ ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីអប់រំពលរដ្ឋបន្ថែមទៀតអំពីក្របខណ្ឌច្បាប់ជុំវិញសេរីភាពខាងការជួបប្រជុំ។

តើនីតិវិធីរបស់រដ្ឋាភិបាល និងតុលាការជួយសម្រួលដល់ការដាក់ពាក្យបណ្តឹងទាក់ទងនឹងការរំលោភសិទ្ធិមនុស្សបានកម្រិតណា?

តើអ្នកយល់ថាមានភាពងាយស្រួលកម្រិតណាក្នុងការដាក់ពាក្យប្តឹងទៅរដ្ឋាភិបាល ឬតុលាការអំពីការរំលោភសិទ្ធិមនុស្ស?



ចន្លោះឆ្នាំ២០២២ ដល់ឆ្នាំ២០២៣ មានការកើនឡើង ៦% នៃអ្នកឆ្លើយតបដែលរាយការណ៍ថាមានការលំបាកច្រើនក្នុងការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្សទៅកាន់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល)។ ការការពារសេរីភាពជាមូលដ្ឋានគឺមានសារៈសំខាន់បំផុត ដែលរដ្ឋត្រូវបង្កើតយន្តការផ្លូវច្បាប់ ដែលតាមរយៈយន្តការនោះសាធារណជនអាចលើកឡើងពីកង្វល់ពីការរំលោភសិទ្ធិមនុស្ស។

ភាគរយនៃអ្នកឆ្លើយថាមានទំនុកចិត្តដែលស្ថាប័នរដ្ឋាភិបាលនឹងដំណោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស



នៅឆ្នាំ២០២៣ មានការថយចុះ ៥% នៃអ្នកឆ្លើយតបដែលឆ្លើយថា "មានទំនុកចិត្ត" ថារដ្ឋាភិបាលនឹងផ្តល់ដំណោះស្រាយមកលើបញ្ហារំលោភសិទ្ធិមនុស្ស។

ភាពខុសគ្នាតាមយេនឌ័រក្នុងការអនុវត្តសេរីភាពមូលដ្ឋាន

ភាគរយអ្នកឆ្លើយតបថាមានសេរីភាពក្នុងការចូលរួមសកម្មភាពនយោបាយ បែងចែកតាមយេនឌ័រ



លទ្ធផលនៃការស្ទង់មតិសាធារណៈបង្ហាញថា អ្នកឆ្លើយថាមានសេរីភាពក្នុងការចូលរួមក្នុងជីវភាពនយោបាយបានថយចុះពីឆ្នាំ២០២២ ដោយថយចុះ២% សម្រាប់បុរស និង ៦% សម្រាប់ស្ត្រីនៅឆ្នាំ២០២៣ ដែលភាពខុសគ្នារវាងបុរសនិងស្ត្រីគឺមាន៩%។ ភាពខុសគ្នារវាងស្ត្រី និងបុរសមានចំនួនប្រហាក់ប្រហែលគ្នានឹងឆ្នាំ២០២១ ប៉ុន្តែចាប់តាំងពីពេលនោះមក ភាពខុសគ្នាបានកើនឡើងដល់កម្រិតគួរឱ្យកត់សម្គាល់ មុនពេលមានការរាតត្បាតនៃកូវីដ-១៩។ ការបង្កើតបរិយាកាសប្រកបដោយបរិយាបន្ន និងការគាំទ្រ មានសារៈសំខាន់ណាស់ក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមពីស្ត្រីក្នុងជីវភាពនយោបាយដើម្បីជានាូវសង្គមដែលប្រកបដោយសមធម៌ និងមានភាពជាតំណាងកាន់តែច្រើន។

ភាគរយនៃអ្នកឆ្លើយតបមានសេរីភាពក្នុងការនិយាយដោយបើកចំហតាមប្រព័ន្ធផ្សព្វផ្សាយ បែងចែកតាមយេនឌ័រ



មានការថយចុះទាំងភាគរយបុរស និងស្ត្រី ដែលឆ្លើយថា "មានសេរីភាព" ឬ "មានសេរីភាពខ្លះដែរ" ក្នុងការនិយាយដោយបើកចំហតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដោយថយចុះមកត្រឹម ៣៦% និង៣៤% ក្នុងឆ្នាំ២០២៣ ដែលភាគរយចំពោះបុរសថយចុះ១១% និង៨% ចំពោះស្ត្រី។ ការរឹតត្បិតខ្លួនឯងដោយសារតែការភ័យខ្លាចនឹងការតបត ឬការយោយីផ្សេងៗ អាចរារាំងដល់ការពិភាក្សា និងការផ្លាស់ប្តូរមតិយោបល់គ្នា ដែលបញ្ហានេះ ប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
SOLIDARITY CENTER
សមាគមអាដហុក
ADHOC
ខែឧសភា ឆ្នាំ២០២៤

CC BY NC SA